## សហភាពអឺរ៉ុប  កម្មវិធីស្បៀងអាហារ

FAO / European Union Food Facility Project

**FAO EU FFP-A02**







# ការកាត់បន្ថយការបាត់បង់ស្រូវ
# ក្រោយពេលប្រមូលផល













**ខែមិថុនា ឆ្នាំ ២០១១**


រៀបចំដោយ: **អគ្គនាយកដ្ឋានកសិកម្ម**

អគារលេខ ៤៥ បេ ផ្លូវលេខ ៦៥៦ សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក ភ្នំពេញ

ទូរស័ព្ទ: ០២៣ ៨៨ ៣២ ៦៧ និង ០២៣ ៩៦ ៩៥ ០០

## កម្មវិធីស្បៀងអាហារសហភាពអឺរ៉ុប (FAO EU Food Facility Project)

គម្រោងការបង្កើនសន្តិសុខស្បៀងសម្រាប់គ្រួសារកសិករ ដែលរងឥទ្ធិពលដោយសារការឡើងថ្លៃស្បៀងអាហារ គឺជាគម្រោងមួយដែលស្ថិតនៅក្នុង កម្មវិធីស្បៀងអាហារ របស់សហភាពអឺរ៉ុប និងផ្តល់មូលនិធិដោយសហភាពអឺរ៉ុប (EU) តាមរយៈ អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តនៅលើខេត្តគោលដៅចំនួន ១០ នៃប្រទេសកម្ពុជា រួមមាន: បន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពង់ធំ ព្រះវិហារ ព្រៃវែង សៀមរាប ស្វាយរៀង តាកែវ និងឧត្តរមានជ័យ។ គោលដៅនៃគម្រោងការនេះ គឺដើម្បីបង្កើនសន្តិសុខស្បៀងដល់គ្រួសារកសិករដែលរងឥទ្ធិពលដោយការឡើងថ្លៃស្បៀងអាហារ តាមរយៈការបង្កើនផលិតភាព កសិកម្ម ដោយផ្អែកលើដំណាំស្រូវ និងពិពិធកម្មកសិកម្ម ការអភិវឌ្ឍន៍វារីវប្បកម្ម ការធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ ការកែលម្អប្រព័ន្ធស្រោចស្រពខ្នាតតូច និងការអភិរក្សធនធានធម្មជាតិ នៅលើកសិករគោលដៅចំនួន ៥០.០០០ គ្រួសារ។

គម្រោងការនេះចាប់ផ្តើមអនុវត្តពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩ ដល់ខែ មិថុនា ឆ្នាំ ២០១១ ដែលមានមូលនិធិចំនួន ១១,២ លានអឺរ៉ូ ប្រហាក់ប្រហែលជាង ១៥ លានដុល្លាសហរដ្ឋអាមេរិក និងគ្រប់គ្រងដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) សហការជាមួយស្ថាប័នរាជរដ្ឋាភិបាលថ្នាក់ជាតិ រួមមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងកិច្ចការនារី រួមទាំងមន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្ត និងអង្គការក្រៅរដ្ឋាភិបាល។

# អារម្ភកថា

អគ្គនាយកដ្ឋានកសិកម្ម ក្រោមកិច្ចសហការ និងគាំទ្រពីកម្មវិធីស្បៀងអាហារ របស់សហភាពអឺរ៉ុប ( FAO EU Food Facility Project) តាមរយៈ គម្រោងការបង្កើនសន្តិសុខស្បៀងសម្រាប់គ្រួសារកសិករ ដែលរងឥទ្ធិពលដោយការឡើងថ្លៃស្បៀងអាហារដែលមានគោលដៅដើម្បីពង្រឹងវិស័យកសិកម្មនិងអាហារូបត្ថម្ភនៅតាមជនបទ។ ការពង្រឹងសមត្ថភាពដែលមានស្រាប់ ដើម្បីអនុវត្តគោលការណ៍សន្តិសុខស្បៀង និងផ្តល់សេវាកម្មអប់រំបន្ថែមសុទ្ធសឹងជាការបង្កើនទិន្នផលកសិកម្មដល់គ្រួសារដែលងាយរងឥទ្ធិពល ដោយការឡើងថ្លៃស្បៀងអាហារតាមរយៈការពង្រឹងចំណេះដឹងដល់ពួកគាត់ និងផ្តល់សំភារៈកសិកម្មដែលមានគុណភាពខ្ពស់។

ឯកសារ **ការកាត់បន្ថយការបាត់បង់ស្រូវក្រោយពេលប្រមូលផល** នេះបានចងក្រងដោយអ្នកជំនាញបច្ចេកទេស នឹងត្រូវបានឆ្លងការពិនិត្យ ពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីអ្នកបច្ចេកទេសពីនាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានកសិកម្ម។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពីព័ត៌មានបច្ចេកទេសវិធីសាស្ត្រ និងនិតិវិធីផ្នែកបច្ចេកវិទ្យាប្រមូលផល សម្រាប់ជួយដល់មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិ នៅមូលដ្ឋាននានាយកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពអោយបានជ្រួតជ្រាបដល់ប្រជាកសិករ និងផលិតករដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពស្របតាមលក្ខខណ្ឌភូមិសាស្ត្រសេដ្ឋកិច្ចសង្គមនិងតម្រូវការជាក់លាក់នៅមូលដ្ឋាន។

ដូច្នេះឯកសារអនុវត្តបច្ចេកវិទ្យានេះមានសារៈប្រយោជន៍រួមសម្រាប់មន្ត្រីកសិកម្មខេត្ត-រាជធានីនិងស្រុកយកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការ បង្កើនសន្តិសុខស្បៀង ការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងកម្មវិធីស្បៀងអាហារ របស់ សហភាពអឺរ៉ុប គាំទ្រនូវឯកសារអនុវត្តបច្ចេកវិទ្យានេះ ដែលជាឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-រាជធានី អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនានានៅតាមមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ យកទៅអនុវត្ត ក្នុងការផ្ទេរ បច្ចេក វិទ្យាដល់ប្រជាកសិករនៅជនបទអោយទូលំទូលាយ និងទទួលបានលទ្ធផលល្អប្រសើរប្រកបដោយក្តីសង្ឃឹម។

ភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១១

**ប្រធានគ្រប់គ្រងគម្រោង**

**ទឹម អេឃើន**

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុក**
**អគ្គនាយកដ្ឋានកសិកម្ម**

**សូ ខនឬទ្ធីគុណ**

# សេចក្តីថ្លែងអំណរគុណ

ឯកសារបណ្តុះបណ្តាលស្តីពី **ការកាត់បន្ថយការបាត់បង់ក្រោយពេលប្រមូលផល** បានរៀបចំឡើងក្រោមការឧបត្ថម្ភគាំទ្រពីកម្មវិធីស្បៀងអាហារ របស់សហភាពអឺរ៉ុប ( FAO EU Food Facility Project) ដែលជាលទ្ធផលនៃការប្រឹងប្រែងរួមគ្នារវាង អង្គការស្បៀង និង កសិកម្មសហប្រជាជាតិ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

ប្រភពធនធានមនុស្សដែលបានចូលរួមជួយរៀបរៀង និងចងក្រងឯកសារបណ្តុះបណ្តាលនេះឡើងដោយបានផ្តល់យោបល់ ប្រឹក្សាបច្ចេកទេស និងពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ដោយមានការពិភាក្សាជាមួយមន្ត្រីជំនាញ បច្ចេកទេសពីនាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានកសិកម្ម មន្ទីរកសិកម្មខេត្ត អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល គ្រូបង្គោលទីប្រឹក្សា បច្ចេកទេសជាតិ និងអន្តរជាតិ នៃគម្រោងកម្មវិធីស្បៀងអាហារ របស់ សហភាពអឺរ៉ុប ក្នុងខេត្តគោលដៅទាំង១០ (ខេត្តកំពង់ស្ពឺ តាកែវ ព្រៃវែង ស្វាយរៀង កំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ឧត្តរមានជ័យ និង ព្រះវិហារ)។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីពាក់ព័ន្ធទាំងអស់ និងអគ្គនាយកដ្ឋានកសិកម្ម ដែលបានចំណាយពេលវេលា ក្នុងការរៀបចំឯកសារបណ្តុះបណ្តាលសហគមន៍កាន់តែមានលក្ខណៈល្អប្រសើរ និងប្រកប ដោយនិរន្តរភាព។

# មាតិកាអត្ថបទ

**ចំណងជើងមេរៀន ទំព័រ**

ផ្នែកទី ១- ការបាត់បង់ស្រូវក្រោយពេលប្រមូលផល ....... ១
១-ការបាត់បង់បរិមាណ ឬ ទំងន់ ....... ១
២-ការបាត់បង់គុណភាព ....... ២
ផ្នែកទី ២- កិច្ចប្រតិបត្តិនានានៅក្រោយពេលប្រមូលផល ....... ៣
១-ការច្រូតកាត់ ....... ៣
២-ការហាលកណ្តាប់នៅក្នុងស្រែមុនពេលបោកបែន ....... ៥
៣-ការបោកបែន ....... ៥
៤-ការហាលសំងួត ....... ៦
៥-ការសំអាតស្រូវ ....... ៨
ផ្នែកទី ៣- បច្ចេកទេសក្នុងការទុកដាក់ស្រូវដោយសុវត្ថិភាព ....... ៩
១-គោលបំណង ....... ៩
២-សីតុណ្ហភាព និងសំណើម ....... ៩
៣-បរិមាណអុកស៊ីហ៊្សែន ....... ៩
៤-ប្រភេទនៃប្រព័ន្ធទុកដាក់ ....... ១០
៥-បច្ចេកទេសក្នុងការទុកដាក់ស្រូវដោយសុវត្ថិភាព ....... ១២
៦-សត្វល្អិត និង ការទប់ស្កាត់ ....... ១៤
៧-សត្វកកេរ-បក្សី និង វិធានការណ៍ការពារ ....... ១៦
៨- ជម្ងឺ ឬ ការដុះផ្សិត ....... ១៨
ផ្នែកទី ៤- ការកិនស្រូវ និង លក្ខណៈគុណភាពស្រូវអង្ករ ....... ២០
១- ការកិនស្រូវ ....... ២០
២- ម៉ាស៊ីនកិនស្រូវ ....... ២១
៣- លក្ខណៈគុណភាពស្រូវអង្ករ ....... ២២
ឯកសារយោង ....... ២៦

**តារាង**

តារាងទី ១: ការបាត់បង់ស្រូវអង្ករជាមធ្យមនៅតំបន់អាស៊ីអាគ្នេយ៍ (គិតជាភាគរយ) ........................................១
តារាងទី ២: អត្រាសំណើមសមស្រប ដើម្បីទុកដាក់ស្រូវធម្មតា និងស្រូវពូជឱ្យមានសុវត្ថិភាព ...............................១២
តារាងទី ៣: អត្រាសំណើមគ្រាប់ធញ្ញជាតិមួយចំនួន ដែលសមស្របសម្រាប់ការទុកដាក់យូរ ...............................១៣

# ផ្នែកទី ១- ការបាត់បង់ស្រូវក្រោយពេលប្រមូលផល

ពាក្យថា "ការបាត់បង់ ឬ ខូចខាតនៅក្រោយពេលប្រមូលផល" មានន័យថាជាការបាត់បង់ទាំងបរិមាណ និងគុណភាពនៃផលិតផលបន្ទាប់ពីការច្រូតកាត់រួច។ ការបាត់បង់នេះ តែងតែកើតមានក្នុងដំណាក់កាលផ្សេងៗនៃប្រព័ន្ធការងារក្រោយប្រមូលផល។ ការប្រើប្រាស់គ្រាប់ពូជស្រូវដែលមានគុណភាពអន់ ការដាំដុះថែទាំមិនបានល្អ ឬការដែលមានសត្វល្អិតបំផ្លាញនៅក្នុងស្រែ អាចបណ្តាលឱ្យមានការបាត់បង់តាំងពីមិនទាន់ប្រមូលផលម្ល៉េះ។

**តារាងទី ១:** ការបាត់បង់ស្រូវអង្ករជាមធ្យមនៅតំបន់អាស៊ីអាគ្នេយ៍ ( គិតជាភាគរយ )

| ដំណាក់កាល | អប្បបរិមា (%) | អតិបរិមា (%) |
|---|---|---|
| ច្រូតកាត់ | ១ | ៣ |
| លើកដាក់ | ២ | ៧ |
| បោកបែន | ២ | ៦ |
| សម្ងួត | ១ | ៥ |
| ទុកដាក់ | ២ | ៦ |
| ដឹកជញ្ជូន | ២ | ១០ |
| **សរុប** | **១០** | **៣៧** |

នៅប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ការបាត់បង់ជារួមនៃគ្រាប់ធញ្ញជាតិនៅក្រោយពេលប្រមូលផលចំនួនពី ១០% ទៅ ១៥% តែងកើតមានជាធម្មតា ។ នៅតំបន់មួយចំនួននៃទ្វីបអាហ្វ្រិក និង អាមេរិកឡាទីន គេបានរកឃើញថា ការបាត់បង់មានអត្រាខ្ពស់ជាងនេះ គឺរហូតដល់ទៅ ៥០% នៃបរិមាណផលិតផលដែលគេប្រមូល។ ជាឧទាហរណ៍ តារាងទី ១ ផ្តល់នូវការប៉ាន់ស្មានលើការខូចខាត និង បាត់បង់ស្រូវអង្ករ ក្នុងដំណាក់កាលនីមួយៗក្រោយពេលប្រមូលផលនៅតំបន់អាស៊ីអាគ្នេយ៍ ។

## ១. ការបាត់បង់បរិមាណ ឬ ទំងន់

ការថយចុះនូវសារធាតុរូបសាស្ត្រនៃផលិតផល គឺជាការបាត់បង់បរិមាណ ឬទំងន់។ ទោះជាដូច្នេះក៏ដោយ គេត្រូវតែញែកឱ្យដាច់រវាងការបាត់បង់ទំងន់ និងការបាត់បង់ផលិតផល។ ការថយចុះនូវអត្រាសំណើម បណ្តាលឱ្យថយចុះទំងន់គ្រាប់ ប៉ុន្តែវាពុំមែនជាការបាត់បង់បរិមាណស្បៀងទេ។ ផ្ទុយទៅវិញការកើនឡើងនូវទំងន់គ្រាប់ដែល